**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 10-Sep-2012, 15:58
CMS/CFO: Uch Arun

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហព្រះរាជអាជ្ញា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១២

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយ កសចស ឬ អង្គជំនុំជម្រះ : **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

# ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ ខៀវ សំផន ស្នើសុំកែសម្រួលបញ្ជីភស្តុតាងជាក់លាក់

---

| អ្នកដាក់ឯកសារ៖ | អ្នកទទួលឯកសារ៖ | ចម្លងជូន៖ |
|---|---|---|
| **សហព្រះរាជអាជ្ញា៖** | **អង្គជំនុំជម្រះសាលាដំបូង៖** | **ជនជាប់ចោទ៖** |
| លោកស្រី ជា លាង | ចៅក្រម **និល ណុន** ជាប្រធាន | នួន ជា |
| លោកAndrew CAYLEY | ចៅក្រម Silvia CARTWRIGHT | អៀង សារី |
| | ចៅក្រម **យ៉ា សុខន** | ខៀវ សំផន |
| | ចៅក្រមJean-Marc LAVERGNE | **មេធាវីការពារក្តី**ជនជាប់ចោទ៖ |

ចៅក្រម **យូរ ឧត្តរា**

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

ពេជ អង្គ

Elisabeth SIMONNEAU FORT

សុន អរុណ

Michiel PESTMAN
Victor KOPPE

អាង ឧត្តម

Michael G. KARNAVAS

គង់ សំអុន

Anta GUISSÉ
Arthur VERCKEN
Jacques VERGÈS

*០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ*

**ចម្លើយតប**

១. កាលពីថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១២ ជនជាប់ចោទ ខៀវ សំផន តាមរយៈសហមេធាវីរបស់គាត់ (“មេធាវីការពារក្តី”) បានធ្វើសារណាជាលាយលក្ខណ៍អក្សរ៖ (ក) គាំទ្រសំណើរបស់ជនជាប់ចោទ អៀង សារី (“សំណើរបស់ អៀង សារី”) ដែលស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូង (“អង្គជំនុំជម្រះ”) សាកសួរអ្នកបកប្រែផ្ទាល់មាត់ដែលបានជួយនៅក្នុងការស្តាប់ចម្លើយសាក្សី ភី ភួន លើកទី២នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត[1] និង (ខ) ស្នើសុំឱ្យអង្គជំនុំជម្រះបង្គាប់ឱ្យសហព្រះរាជអាជ្ញា កែសម្រួលបញ្ជីចម្លើយជាលាយលក្ខណ៍អក្សររបស់ ខ្លួនដែលត្រូវបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះជំនួសឱ្យសក្ខីកម្មផ្ទាល់មាត់[2]។ សហព្រះរាជអាជ្ញាបានឆ្លើយតបទៅនឹងសំណើរបស់ អៀង សារី កាលពីថ្ងៃទី ៤ ខែកញ្ញា ឆ្នាំ២០១២ និងដាក់បញ្ចូលជាឯកសារយោងនូវសារណាទាំងឡាយតប ទៅនឹងកថាខណ្ឌ ១-៤ និង ២៣ (bullet 1) នៃសំណើរបស់ ខៀវ សំផន[3]។ នៅពេលនេះ សហព្រះរាជអាជ្ញាសូមឆ្លើយតបទៅនឹងកថាខណ្ឌ ៥-២២ និង ២៣ (bullet 2) នៃសំណើដដែលនេះ។

---

[1] E223 មតិគាំទ្រសំណើរបស់លោក អៀង សារី E221 និងស្នើសុំដល់អង្គជំនុំជម្រះសាលាដំបូងឱ្យបង្គាប់ដល់សហព្រះរាជអាជ្ញា ធ្វើការកែតម្រូវបញ្ជីសក្ខីកម្មជាលាយលក្ខណ៍អក្សរ ដែលសហព្រះរាជអាជ្ញាមានបំណងដាក់បញ្ចូលក្នុងការពិភាក្សាដេញដោលជំនួសឱ្យសក្ខីកម្មផ្ទាល់មាត់ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១២ កថាខណ្ឌ ១-៤ (“សំណើ”)។ យោងឯកសារ E221 សំណើរបស់អៀង សារី សុំស្តាប់ការបង្ហាញភស្តុតាងពីអ្នកបកប្រែផ្ទាល់មាត់ ពាក់ព័ន្ធនឹងការស្តាប់ចម្លើយសាក្សី ភី ភួន លើកទីពីររបស់ ក.ស.ច.ស ដែលកើតមាននូវភាពមិនប្រក្រតី ដែលអាចនឹងចាត់ទុកថាជាការលេងល្បិចឆ្នែក ចុះថ្ងៃទី ២៣ ខែសីហា ឆ្នាំ២០១២។

[2] E223, *ដូចដើងទំព័រខាងលើ* កថាខណ្ឌ៥-២៣។ យោងឯកសារ E96/8 សំណើបន្ថែមរបស់សហព្រះរាជអាជ្ញា ដើម្បីដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនូវកំណត់ហេតុជាលាយលក្ខណ៍អក្សរ និងប្រតិចារឹក ជាមួយនឹងឧបសម្ព័ន្ធសម្ងាត់ពី ១-១៦ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១២ (“សំណើបន្ថែមរបស់សហព្រះរាជអាជ្ញា”)។ E208 សំណើរបស់សហព្រះរាជអាជ្ញាស្នើសុំឱ្យទទួលយកចម្លើយ សាក្សីពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជននៅដំណាក់កាលទី១ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១២ និង E208/2 សំណើរបស់សហ ព្រះរាជអាជ្ញាសុំឱ្យទទួលយកចម្លើយសាក្សីនានា ដែលទាក់ទងនឹងដំណាក់កាលទី២ នៃការជម្លៀសប្រជាជន និងបញ្ជាភ័ស្តុតាងផ្សេង ទៀតជាមួយនឹងឧបសម្ព័ន្ធសម្ងាត់ I, II, III និងឧបសម្ព័ន្ធ IV សាធារណៈ ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១២។

[3] E221/1 ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ក្រុមមេធាវីការពារក្តី អៀង សារី ស្នើឱ្យស្តាប់ការបង្ហាញភ័ស្តុតាងពីអ្នកបកប្រែផ្ទាល់មាត់ ពាក់ព័ន្ធនឹងការស្តាប់ចម្លើយសាក្សី ភី ភួន លើកទីពីរ ធ្វើឡើងដោយ ក.ស.ច.ស ចុះថ្ងៃទី៤ ខែ កញ្ញា ឆ្នាំ ២០១២។

២. បញ្ហាបឋម សហព្រះរាជអាជ្ញាសង្កេតឃើញថាមេធាវីការពារក្ដីព្យាយាមជំទាស់ទៅនឹងសារណាជាលាយលក្ខណ៍អក្សរ ដែលត្រូវបានដាក់ក្នុងកំឡុងពេល ចាប់ពីថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ២០១២ ដល់ថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១២ ដែលហួសរយ:ពេលដែលបានទុកអោយសម្រាប់ការឆ្លើយតបដូចបានកំណត់ នៅក្នុងសេចក្ដីណែនាំការអនុវត្តនានាដែលពាក់ព័ន្ធ[4] ហើយដែលស្ដែងអោយឃើញនូវ ការមិនសូវគោរពចំពោះសេចក្ដីណែនាំរបស់អង្គជំនុំជម្រះចុះថ្ងៃទី ២០ ខែមិថុនា ឆ្នាំ ២០១២ ដែលនៅ ក្នុងសេចក្ដីសម្រេចនោះអង្គជំនុំជម្រះបានគូសបញ្ជាក់ថាខ្លួន "គ្រោងកំណត់កាលបរិច្ឆេទសវនាការ ឬ *ផ្ដល់ឱកាស* ដើម្បីដាក់សេចក្ដីជំទាស់នានាដែលពាក់ព័ន្ធនឹងភស្តុតាង ដែលសហព្រះរាជអាជ្ញាស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះ"[5]។

៣. ជារួម មេធាវីការពារក្ដីជំទាស់ទៅនឹងការទទួលយកចម្លើយជាលាយលក្ខណ៍អក្សរ ដែលសហព្រះរាជអាជ្ញាបានស្នើឡើងដោយមូលហេតុថាឯកសារចម្លើយទាំងនេះមានចំនួនច្រើនពេក ហើយត្រូវការពេលវេលាយ៉ាងយូរដែលមិនអាចទទួលយកបានដើម្បីបកប្រែ ដើម្បីពិនិត្យមើលឡើងវិញ និងដើម្បីធ្វើការជំទាស់ដែលនាំអោយអូសបន្លាយកិច្ចដំណើរការនីតិវិធីសវនាការហួសហេតុពេក[6]។ ជាការឆ្លើយតបសហព្រះរាជអាជ្ញាសូមបញ្ជាក់ថាជំហរបែបនេះរបស់មេធាវីការពារក្ដីគឺពុំត្រឹមត្រូវទាំងអង្គហេតុក៏ដូចជាពុំមានមូលដ្ឋានច្បាស់លាស់តាមអង្គច្បាប់។ បន្ថែមពីលើនេះ មេធាវីការពារក្ដីនៅតែអះអាងថាពុំមានពេលវេលាសម្រាប់ពិនិត្យមើលឡើងវិញលើចម្លើយជាលាយលក្ខណ៍អក្សរទាំងនេះទេ ប៉ុន្តែបែរជាយល់ថាខ្លួនមានលទ្ធភាពជំទាស់ទៅនឹង ភាពពាក់ព័ន្ធ និងភាពអាចជឿជាក់បាននៃចម្លើយទាំងអស់នេះទៅវិញ[7]។ ជាការឆ្លើយតបចំណុចនេះ សហព្រះរាជអាជ្ញាសូមអះអាងជាថ្មីម្ដងទៀតថាចម្លើយជាលាយ

---

[4] សេចក្ដីណែនាំអនុវត្តនៅ អ.វ.ត.ក/០១/២០០៧/វិសោធនកម្មទី៨ ស្ដីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក មាត្រា ៨.៣។

[5] E96/7សេចក្ដីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្ដាប់ចម្លើយសាក្សី និងឯកសារនានានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ ២០១២ ត្រង់កថាខណ្ឌ ៣៦ ("សេចក្ដីសម្រេចលើភាពអាចទទួលយកបាន")។

[6] សូមមើលជាពិសេស E223 សំណើ *យោងខាងលើ* កំណត់សម្គាល់ ១ ត្រង់កថាខណ្ឌ ៦-៧, ៩, ១១, ១៤ និង ២១។

[7] សូមមើលជាពិសេស E223 សំណើ, *ដូចដើងទំព័រខាងលើ* ត្រង់កថាខណ្ឌ ១២,១៦-២១។

លក្ខណ៍អក្សរដែលសហព្រះរាជអាជ្ញាព្យាយាមដាក់នៅចំពោះមុខអង្គជំនុំជម្រះ បំពេញបាននូវលក្ខខណ្ឌតម្រូវនៃភាពពាក់ព័ន្ធ និងភាពអាចជឿជាក់បាន និងការពាក់ព័ន្ធផ្ទាល់ទៅនឹងបញ្ហាដែលអង្គជំនុំជម្រះនឹងពិចារណានៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ ហេតុផលដែលនាំអោយអង្គជំនុំជម្រះបានទទួលយកសំណើ[8]មិនរាប់បញ្ចូល នូវសកម្មភាព និងទង្វើរបស់ជនជាប់ចោទទេ។ សំណើរបស់មេធាវីការពារក្តីនឹងត្រូវបានយកមកពិចារណាដូចខាងក្រោមនេះ។

៤. ជាបឋម មេធាវីការពារក្តីអះអាងថាមានឯកសារច្រើនណាស់នៅមិនទាន់បានបកប្រែនៅឡើយ ហើយតម្រូវការបកប្រែនឹងអូសបន្លាយពេលវេលាសវនាការកាន់តែយូរ៖

[...] *ស្ទើរតែពុំមានបណ្តឹងណាមួយក្នុងចំណោមបណ្តឹងទាំង ៤២០ របស់ជនរងគ្រោះដែលសហព្រះរាជអាជ្ញា មានបំណងដាក់ចូលក្នុងកិច្ចពិភាក្សាដេញដោល ត្រូវបានបកប្រែជាភាសាបារាំងនោះទេ រួមបញ្ចូលទាំងឯកសារសក្ខីកម្មមិនតិចជាង ១០០ ឯកសារទៀត ដែលទទួលបានពីមជ្ឈមណ្ឌលឯកសារកម្ពុជា ឬពីសាលាសម្រាប់ការសិក្សាបូព៌ា និងអាហ្វ្រិក* (School of Oriental and African Studies) (SOAS)[9]។

៥. មេធាវីការពារក្តីបានបំភ្លើសហួសពីការពិតយ៉ាងខ្លាំង អំពីវិសាលភាពនៃបន្ទុកក្នុងការបកប្រែ បណ្តាលមកពីសំណើរបស់សហព្រះរាជអាជ្ញាដែលសុំដាក់ចម្លើយជាលាយលក្ខណ៍អក្សរ នៅចំពោះមុខអង្គជំនុំជម្រះ ។ ដូចដែលបានលើកឡើងកន្លងមក[10]ពេលវេលាដែលត្រូវការសម្រាប់ការបកប្រែបណ្តឹងទាំងនោះគឺ តិចតួចទេ ព្រោះថាក្នុងចំណោមពាក្យបណ្តឹងមួយដែលមានចំនួន៧ទំព័រមានតែ០១ទំព័រប៉ុណ្ណោះដែលរៀបរាប់ជាក់ស្តែងអំពីឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ និងដែលចាំបាច់ត្រូវបកប្រែនោះ។ ជាងនេះទៀតមានត្រឹមតែមួយភាគតូចនៃឯកសារភស្តុតាងដែលបានលើកឡើងដោយ សហព្រះរាជអាជ្ញា តែប៉ុណ្ណោះ ដែលពុំទាន់ត្រូវបានបកប្រែជា០៣ភាសានៃភាសាការងាររបស់អ.វ.ត.ក។

---

[8] E96/7 សេចក្តីសម្រេចលើភាពអាចទទួលយកបាន, *យោងខាងលើ* កំណត់សម្គាល់ ៥ ត្រង់កថាខណ្ឌ ២២។

[9] E223 សំណើ *យោងខាងលើ* កំណត់សម្គាល់ ១ ត្រង់កថាខណ្ឌ២០ [បកប្រែបណ្តោះអាសន្នពីភាសាបារាំង]។

[10] ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១២ ត្រង់កថាខណ្ឌ ២៥។

*ក្នុងចំណោមប្រតិចារឹកនៃសក្ខីកម្មនាពេលសវនាការទាំង ៤០ ដែលបានស្នើឲ្យទទួលយកទាំងអស់សុទ្ធតែមានជា០៣ភាសាការងាររបស់ អ.វ.ត.ក រួចហើយ*[11]*។ នៅក្នុងចំណោមកំណត់ហេតុទាំង ៥២៦ ដែលបានស្នើឡើងដើម្បីឲ្យយល់ព្រមទទួលយក សុទ្ធតែមានស្រាប់ដែលអាចងាយរកបានជា០៣ភាសានៃភាសាការងាររបស់ អ.វ.ត.ក ដែលមានមួយបកប្រែជាភាសាខ្មែរ និងបួនបកប្រែជាភាសាបារាំង*[12]*។*

៦. ទីពីរ មេធាវីការពារក្តីបានអះអាងថា បរិមាណឯកសារបានស្នើរឡើងជាបញ្ហា ធ្វើឲ្យមាន ពេលវេលាមិនគ្រប់គ្រាន់ដើម្បី ពិនិត្យឡើងវិញអោយបានជាក់លាក់នូវឯកសារនីមួយៗ ក្នុងន័យ ឆ្លើយតបអោយបាននូវលក្ខខណ្ឌនៃការបំពេញកាតព្វកិច្ចប្រកបដោយការយកចិត្តទុកដាក់ និងភាពហ្មត់ចត់[13]។ សហព្រះរាជអាជ្ញា សូមជូនសេចក្តីសន្និដ្ឋានថា អំណះអំណាងរបស់មេធាវីការពារក្តី គឺគ្មានមូលដ្ឋានអង្គសេចក្តីទាំងស្រុងតែម្តង ជាពិសេស គឺនៅក្នុងបរិបទនៃច្បាប់នីតិវិធីព្រហ្មទណ្ឌ ដែលកំពុងអនុវត្តនៅចំពោះមុខ អ.វ.ត.កតែម្តង។ ការលើកឡើងថាពុំមាន ពេលគ្រប់គ្រាន់ណាមួយ គឺគ្រាន់តែជាការសន្មតតែឯង និងដោយផ្ទាល់របស់ មេធាវីការពារក្តីតែប៉ុណ្ណោះ ដែលការអះអាងរបស់គាត់នៅពេលនេះគឺមិនអាចផ្អែកលើលក្ខខណ្ឌតម្រូវនៃការយកចិត្តទុកដាក់ ដើម្បីជំរុញឲ្យមានការយកចិត្តទុកដាក់ប្រកបដោយភាពហ្មត់ចត់ ដែលគាត់ចង់បាននោះទេ។

៧. វិធាន៥៨.១ នៃវិធានផ្ទៃក្នុង ចែងថា តាមរយៈមេធាវីរបស់ខ្លួន ជនត្រូវចោទអាចពិនិត្យមើល សំណុំរឿងបាន យ៉ាងហោចណាស់ប្រាំ(០៥)ថ្ងៃ មុនពេលសួរចម្លើយលើកទីមួយ៖

> *នៅពេលជនត្រូវចោទមានមេធាវី សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកាកោះហៅមេធាវី យ៉ាង តិចបំផុត ៥ (ប្រាំ)ថ្ងៃ មុនពេលធ្វើការសួរចម្លើយ។ ក្នុងអំឡុងពេលនេះ មេធាវីអាចពិនិត្យមើលសំណុំរឿងបាន។*

ជនជាប់ចោទ ខៀវ សំផន ដែលត្រូវបានចោទប្រកាន់កាលពីថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧ ហើយមានលទ្ធភាពអាចពិនិត្យ មើលសំណុំរឿងបានតាមរយៈមេធាវីរបស់ខ្លួនចាប់តាំងពីថ្ងៃនោះមក។

---

[11] E96/8 សំណើបន្ថែមរបស់សហព្រះរាជអាជ្ញា *យោងខាងលើ* កំណត់សម្គាល់ ២ ត្រង់កថាខណ្ឌ ២១។

[12] E96/8 *ដូចជើងទំព័រខាងលើ* ត្រង់កថាខណ្ឌ២២។

[13] E223 សំណើ, កំណត់សម្គាល់*ខាងលើ*លេខ១ ត្រង់កថាខណ្ឌទី ៧, ៩។

វិធាន៥៥.៧ នៃវិធានផ្ទៃក្នុង ចែងថាការពិនិត្យមើលសំណុំរឿងនេះអាចធ្វើបានគ្រប់ពេលវេលានៃដំណាក់កាលការស៊ើបសួរ។

> *ក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេត ត្រូវរក្សាទុកសំណុំរឿង រួមទាំងកំណត់ហេតុ និង របាយការណ៍នៃការស៊ើបសួរ។ សហព្រះរាជអាជ្ញា និង មេធាវីរបស់ភាគីទាំងអស់ មានសិទ្ធិគ្រប់ពេលវេលាក្នុងការពិនិត្យ និង ថតចម្លងសំណុំរឿង ក្រោមការឃ្លាំមើលរបស់ ក្រឡាបញ្ជីនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ក្នុងពេលម៉ោងធ្វើការ និងគោរពទៅ តាមបទបញ្ជារបស់អង្គជំនុំជម្រះវិសាមញ្ញ។*

វិធាន៨៦ នៃវិធានផ្ទៃក្នុង ចែងថា សិទ្ធិរបស់ជនជាប់ចោទស្តីពីការពិនិត្យមើលសំណុំរឿងនៅគ្រប់ពេលវេលានៃកិច្ចដំណើរការនីតិវិធីសវនាការ :

> *នៅគ្រប់ពេលវេលា សហព្រះរាជអាជ្ញា និង មេធាវីរបស់ភាគីទាំងអស់ ត្រូវមានសិទ្ធិពិនិត្យមើល និង ថតចម្លងសំណុំរឿង ដោយស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ក្រឡាបញ្ជីនៃ អង្គជំនុំជម្រះសាលាដំបូង នៅពេលម៉ោងធ្វើការ និង ត្រូវគោរពទៅតាមលក្ខខណ្ឌតម្រូវ សម្រាប់ដំណើរការល្អរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។*

៨. ដូច្នេះគ្រប់ទម្រង់នៃការការពារ និង បែបបទនីមួយៗត្រូវបានផ្តល់ជូនអោយមេធាវីការពារក្តីចាប់តាំងពីខែវិច្ឆិកា ឆ្នាំ២០០៧មកម្ល៉េះ ដើម្បីអនុញ្ញាត្តិអោយមានលទ្ធភាពក្នុងការអនុវត្តបានត្រឹម ត្រូវនូវកាតព្វកិច្ចប្រកបដោយការយកចិត្តទុកដាក់ និង ភាពហ្មត់ចត់នៅក្នុងការវាយតម្លៃលើឯកសារគ្រប់ប្រភេទទាំងអស់ ដែលសហព្រះរាជអាជ្ញាបានស្នះស្វែងដាក់ជូននៅចំពោះមុខអង្គជំនុំជម្រះនៅពេលនេះ។ ជាពិសេសនៅក្នុងសំណើរបស់ខ្លួន មេធាវីការពារក្តីបានលើកឡើងដដែលៗយ៉ាងស្រគៀត្រចៀក ពីការពុំមានពេលវេលា គ្រប់គ្រាន់ដើម្បីធ្វើការពិនិត្យពិច្ច័យ លើកំណត់ហេតុស្តាប់ចម្លើយ សាក្សី ទាំងនោះដែលបានផ្តល់ជូនដោយការិយាល័យសហចៅក្រមស៊ើបអង្កេត "ក.ស.ច.ស" ដែលសហព្រះរាជអាជ្ញាបានស្នះស្វែង ដាក់ចំពោះមុខអង្គជំនុំជម្រះ[14](គឺថាកំណត់ហេតុទាំងនោះដែល បានផ្តល់ដោយ សាក្សីនានាដែលគេមិនរំពឹងថានឹងត្រូវកោះហៅឲ្យចូលខ្លួននៅចំពោះមុខអង្គជំនុំជម្រះ)។ ពិន្ទុរេខីយ (chart) ដែលការិយាល័យសហព្រះរាជអាជ្ញាបានរៀបចំ **(ឧបសម្ព័ន្ធ១)** មានសេចក្តីសង្ខេប ពីចំណាត់ថ្នាក់កំណត់ហេតុទាំងនេះទៅតាមការកំណត់ពេលតៗគ្នា(staggered placement of these statements) ហើយនិងការបកប្រែភាសាជាផ្លូវការមាននៅក្នុងសំណុំរឿង។ ពិន្ទុរេខីយនេះ (this

[14] E223 សំណើ, កំណត់សម្គាល់*ខាងលើ*លេខ១ ត្រង់កថាខណ្ឌទី ៧- ៩។

chart) បង្ហាញយ៉ាងច្បាស់ថាកំណត់ហេតុស្តាប់ចម្លើយទាំងអស់ លើកលែងតែ៤៨កំណត់ហេតុប៉ុណ្ណោះ ដែលមេធាវីការពារក្តី បានអះអាងនៅពេលនេះថាចាំបាច់ត្រូវពិនិត្យឡើងវិញ នោះ តាមពិតទៅ មេធាវីការពារក្តីអាចពិនិត្យមើលបានរួចជាស្រេច *ទាំងជាភាសាខ្មែរ និងទាំង ជាភាសាបារាំង តាំងពីជាងពីរឆ្នាំកន្លះមកម៉្លេះ* គឺតាំងពីមុនមានដីកាដំណោះស្រាយ។ កំណត់ហេតុ ដែលនៅសេសសល់ មេធាវីការពារក្តីអាចពិនិត្យមើលបាន*តាំងពីជាងមួយឆ្នាំកន្លះមកម៉្លេះ*។ ការខកខានណាមួយដែលមិនបាន ពិនិត្យមើលសំណុំរឿងឱ្យបានត្រឹមត្រូវ ដើម្បីធ្វើការពិនិត្យជា បន្តបន្ទាប់ និងឱ្យទាន់ពេលវេលា ឬ ដើម្បីធ្វើការធានាពីការសម្របសម្រួលរវាងសហមេធាវី គឺជាការសន្មតរបស់មេធាវីការពារក្តីតែឯង និងដោយត្រង់ៗពីហានិភ័យទាំងឡាយ ដែលបន្ទុចបង្អាក់ដល់ការអនុវត្តសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបាននូវការកាត់សេចក្តីដ៏ត្រឹមត្រូវ។ នៅក្នុងសេចក្តីសន្និដ្ឋានប្រកបដោយក្តីគោរពរបស់សហព្រះរាជអាជ្ញាគឺថាទង្វើរបែបនេះរបស់មេធាវីការពារក្តីមិនអាចបង្កើតនូវមូលដ្ឋាននៃការអះអាងណាមួយដែលអាចបញ្ជាក់ពីភាពមិនគ្រប់គ្រាន់នៃពេលវេលានៅក្នុងដំណាក់កាលកិច្ចដំណើរការនីតិវិធីនៅពេលនេះទេ។

៩. ទីបី មេធាវីការពារក្តីបានលើកឡើងតវ៉ាថា ការដាក់ជូននូវឯកសារនានារបស់សហព្រះរាជអាជ្ញាត្រូវតែដាក់នៅបំពោះមុខអង្គជំនុំជម្រះ៖

> [...]*នឹងតម្រូវឱ្យអង្គជំនុំជម្រះសាលាដំបូង ចំណាយពេលវេលាដ៏មានតម្លៃក្នុងការចាត់ចែងរៀបចំថ្ងៃសំរាប់សវនាការ ប្រយោជន៍ដើម្បីឱ្យភាគីនានាអាចធ្វើការជំទាស់របស់ខ្លួន*[15]។

មេធាវីការពារក្តីពោលអះអាងថា បរិមាណនៃឯកសារនិងពេលវេលាដែលមាន នឹងគ្រាន់តែអនុញ្ញាតឱ្យសំរាប់តែបង្កើតឡើងនូវការជំទាស់ជាទូទៅតែប៉ុណ្ណោះ[16]។ សហព្រះរាជអាជ្ញាសូមជូនសេចក្តីសន្និដ្ឋាន ថាសេចក្តីណែនាំរបស់អង្គជំនុំជម្រះនៅក្នុងបញ្ហានេះបានចែងយ៉ាងច្បាស់អំពីសវនាការ ឬ អំពីមធ្យោបាយផ្សេងៗទៀតក្នុងការធ្វើការជំទាស់ចំពោះភស្តុតាង។ ការជំទាស់ទាំងឡាយដែលបានដាក់ជាលាយលក្ខណ៍អក្សរអាចត្រូវបានរៀបចំចាត់ចែងយ៉ាងល្អ និង ដោយជាក់លាក់ដោយគ្មានការអូសបន្លាយពេលវេលានៃដំណើរការសវនាការដោយមិនត្រឹមត្រូវនោះឡើយ។ លើសពីនេះ ការដាក់នូវការជំទាស់ផ្សេងៗ ជាលាយលក្ខណ៍អក្សរគឺមានលក្ខណសម្ប័ម្យជាងគេចំពោះករណីរឿងក្តីដែលមានលក្ខណៈស្មុគស្មាញដែលក្នុងនោះរួមមានភស្តុតាងជាឯកសារយ៉ាងច្រើនដែលត្រូវដាក់បន្ថែម

---

[15] E223 សំណើសុំ *ដូចគ្នានឹងខាងលើ* ត្រង់កខថាខណ្ឌទី៩[បកប្រែបណ្តោះអាសន្នពីភាសាបារាំង]។

[16] E223 សំណើសុំ *ដូចគ្នានឹងខាងលើ* ត្រង់កខថាខណ្ឌទី១៤។

ពីលើការផ្តល់សក្ខីកម្មផ្ទាល់មាត់លើបញ្ហាទាក់ទងនឹងអង្គច្បាប់ជាច្រើននៅក្នុងពេលសវនាការដែលមិនទាក់ទងទៅនឹងអំពើ និងការប្រព្រឹត្តរបស់ជនជាប់ចោទ។

១០. ទីបួនទន្ទឹមធ្វើការតវ៉ាជំទាស់អំពីបញ្ហាស្តីពីពេលវេលាដែលមានសំរាប់ឲ្យធ្វើការបកប្រែ ពិនិត្យមើលឡើងវិញ និងធ្វើការជំទាស់ចំពោះឯកសារដែលកំពុងមានបញ្ហា មេធាវី ការពារក្តីបានលើកឡើងថែមទៀតថាថា ឯកសារដដែលៗទាំងនេះគ្មានទាំងភាពជាប់ទាក់ទងគ្នា និងទាំងភាពគួរឲ្យជឿទុកចិត្តបាន។ តក្កភាពនៃការលើកសំអាងនេះ មិនអាចឲ្យរក្សាជំហររបស់ខ្លួនបានទេ។ទោះបីជាយ៉ាងណាក៏ដោយក៏សហព្រះរាជអាជ្ញា សូមបញ្ជាក់ឡើងវិញសារជាថ្មីថាឯកសារទាំងនេះបានបំពេញទាំងស្រុងទៅតាមលក្ខខណ្ឌតម្រូវស្តីពីភាពជាប់ទាក់ទង និងភាពគួរឲ្យជឿទុកចិត្តបាន ដែលនៅក្នុងលក្ខណៈវិនិច្ឆ័យសំរាប់ការទទួលយក ដែលបានអនុម័តយកដោយអង្គជំនុំជម្រះ កាលពីថ្ងៃទី២០ ខែមិថុនាឆ្នាំ២០១២ហើយ[17]។

១១. ចំពោះភាពជាប់ទាក់ទងនេះ សហព្រះរាជអាជ្ញាសូមជូនសេចក្តីសន្និដ្ឋានថា រាល់ឯកសារទាំងអស់ដែលកំពុងមានបញ្ហា គឺជាប់ទាក់ទងទៅនឹងបញ្ហាពាក់ព័ន្ធនឹងអង្គហេតុ ដែលត្រូវធ្វើការសម្រេចនៅក្នុងវិសាលភាពនៃសវនាការក្នុងពេលបច្ចុប្បន្ននេះ ដូចដែលបានកំណត់ដោយអង្គជំនុំជម្រះ[18] ហើយដែលបានសបញ្ជាក់ ឲ្យឃើញច្បាស់នៅក្នុងអត្ថបទនៃសេចក្តីពន្យល់បន្ថែមមួយនៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ (**ឧបសម្ព័ន្ធទី២**)។ ឯកសារទាំងនេះរួមមានឯកសារដែលជាប់ពាក់ព័ន្ធដោយផ្ទាល់ទៅនឹងដំណាក់កាលដំបូងទាំងពីរ នៃការជម្លៀសប្រជាជន។ នៅពេលដែលចម្លើយសាក្សីមួយចំនួន អាចនឹងពាក់ព័ន្ធទៅនឹងទីតាំងឧក្រិដ្ឋកម្ម ដែលមិនស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿងលេខ០០២/០១ទេ ឯកសារដែលនៅសល់ទាំងនេះជាប់ពាក់ព័ន្ធនឹងដំណើរការនីតិវិធីបច្ចុប្បន្ននេះដដែល។ ដោយសារតែ(ក) លក្ខណៈត្រួតគ្នានៃសក្ខីកម្មផ្ទាល់មាត់របស់សាក្សី ទៅតាមន័យដែលនៅក្នុងសេចក្តីសម្រេចចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១២ របស់អង្គជំនុំជម្រះ[19]។ ឬមួយក៏ (ខ) លក្ខណៈស៊ីសង្វាក់គ្នាជាមួយនឹងភស្តុតាងផ្សេងទៀតដែលនៅចំពោះមុខអង្គជំនុំជម្រះទាក់ទងទៅនឹងបញ្ហាទាំងឡាយដែលស្ថិតនៅក្នុងវិសាលភាពនៃសវនាការជំនុំជម្រះក្តីដែលរួមមាន: (i) ទាក់ទងទៅនឹងប្រវត្តិដើម នៃប្រវត្តិសាស្ត្រ, នយោបាយ, យោធានៃព្រឹត្តិការណ៍ផ្សេងៗនៅក្នុងអម្លុងនៃរបបកម្ពុជាប្រជាធិបតេយ្យ។ (ii)ខ្លឹមសារ

---

[17] E96/7 សេចក្តីសម្រេចស្តីពីភាពអាចទទួលយកបាន, កំណត់សម្គាល់លេខ ៥ *ខាងដើម* ត្រង់កថាខណ្ឌទី៣៥។

[18] E124/7.2 ឧបសម្ព័ន្ធ ៖ បញ្ជីកថាខណ្ឌ និងសមាត្រនៃដីកាដំណោះស្រាយដែលទាក់ទងនឹង សវនាការលើកទី១ លើសំណុំរឿងលេខ០០២, ដែលត្រូវបានកែប្រែបន្ថែមពីលើសេចក្តីសម្រេចស្តីពីបញ្ហាខាងកាយសម្បទា និង ខាងសតិបញ្ញាស្មារតីរបស់ អៀងធីរិទ្ធ ដើម្បីចូលរួមសវនាការ។

[19] E96/7 សេចក្តីសម្រេចស្តីពីភាពអាចទទួលយកបាន, កំណត់សម្គាល់លេខ ៥ *ខាងដើម* ត្រង់កថាខណ្ឌទី២៤(ក)។

នៃធាតុផ្សំ(គឺថា"លក្ខខណ្ឌកម្រិត"[20])បទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និង(iii) លក្ខណ្ឌតម្រូវតាមច្បាប់នៃវិធីទទួលខុសត្រូវចំពោះសហកម្មឧក្រិដ្ឋកម្មរួម ("JCE") ជាពិសេសអត្ថិភាពនៃ ផែនការរួម ដែលក្រសោបនូវគោលនយោបាយគន្លឹះនានា)។ ជាពិសេសការជំទាស់របស់មេធាវីការពារក្តីចំពោះឧបសម្ព័ន្ធពីទី១០ ដល់ទី១៦ នៃការដាក់ជូនឯកសាររបស់សហព្រះរាជអាជ្ញា កាលពីថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ២០១២ ត្រូវតែបរាជ័យដោយសារតែមូលដ្ឋាននេះ[21]។

១២. ដើម្បីភាពច្បាស់លាស់ សហព្រះរាជអាជ្ញា សូមបញ្ជាក់ម្តងទៀតថា នៅក្នុងចម្លើយ និងសក្ខីកម្មជាលាយលក្ខណ៍អក្សរមួយចំនួនដែលកំពុងតែមានបញ្ហាក៏មានភស្តុតាងដែលទាក់ទងនឹងអំពើ និងការប្រព្រឹត្តរបស់ជនជាប់ចោទដែរ ប៉ុន្តែនេះមិនមែនជាគោលបំណងនៃការដាក់ជូនឯកសារទាំងនេះនៅចំពោះមុខអង្គជំនុំជម្រះនោះឡើយ[22]។ ផ្ទុយទៅវិញឯកសារទាំងនេះមានបំណងចង់បង្ហាញភស្តុតាងឱ្យឃើញអំពីអត្ថិភាពនៃគោលនយោបាយ និងរចនាសម្ព័ន្ធនានាជាទូទៅដែលស្ថិតនៅក្នុងវិសាលភាពនៃសវនាការជំនុំជម្រះក្តីនេះ។ អង្គជំនុំជម្រះបានទទួលស្គាល់រួចហើយអំពីភាពដាច់ដោយឡែកពីគ្នារវាងអំពើនិងការប្រព្រឹត្តរបស់ជនជាប់ចោទ ហើយនឹងគោលនយោបាយ និងរចនាសម្ព័ន្ធទូទៅនៅក្នុងការអនុវត្តទាក់ទងនឹងភស្តុតាងរបស់តុលាការ ICTY[23] ហើយដែលភាពដាច់ដោយឡែកពីគ្នានេះមកអនុវត្តសម្រាប់ការទទួលយកឯកសារនានា នៅក្នុងសវនាការ ។

១៣. ទាក់ទិននឹងការទទួលខុសត្រូវ សហព្រះរាជអាជ្ញាមានចំណាប់អារម្មណ៍ជាបឋមលើយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១២ ដែលមេធាវីការពារក្តីហាក់ដូចជាពន្យា នៅក្នុងការអនុវត្តន៍របស់ខ្លួនចំពោះកត្តាផ្សេងៗ ដែលប៉ះពាល់ដល់ភាពជឿទុកចិត្តបាននៃប្រភេទឯកសារភស្តុតាងដែលបានដាក់ជូន។អង្គជំនុំជម្រះបានសម្រេចថា ប្រតិចារឹកពីសំណុំរឿង០០១ គឺមានជាប់មកជាមួយនូវភាពអាចជឿទុកចិត្តបាន ហើយក្នុងកាលៈទេសខ្លះ ថែមទាំងអនុញ្ញាតឱ្យប្រើប្រាស់ភាពជឿទុកចិត្តនេះ ដើម្បីកំណត់នូវសកម្មភាព និងអំពើប្រព្រឹត្តរបស់ជនជាប់ចោទទៀតផង[24]។ អង្គជំនុំជម្រះបានបញ្ជាក់អះអាងថា កំណត់ហេតុស្តាប់ចម្លើយសាក្សីរបស់ កសចស មានផ្ទុកនូវសច្ចៈ

---

[20] E96/7 ដូចគ្នានឹងខាងលើត្រង់កថាខណ្ឌទី២៤(ខ) ។

[21] E223 សំណើសុំ, កំណត់សម្គាល់លេខ ១ *ខាងដើម* ត្រង់កថាខណ្ឌទី១២។

[22] E96/8 សំណើបន្ថែមរបស់សហព្រះរាជអាជ្ញា កំណត់សម្គាល់ខាងលើលេខ២ កថាខណ្ឌ១៧

[23] E96/7 សេចក្តីសម្រេចស្តីពីភាពអាចទទួលយកបាន, កំណត់សម្គាល់លេខ ៥ *ខាងដើម* ត្រង់កថាខណ្ឌទី២១។

[24] E96/7 *ដដែលដូចខាងលើ* ត្រង់កថាខណ្ឌទី៣០-៣១។

ធារណ៍នៃភាពជឿទុកចិត្តបាន និងភាពពាក់ព័ន្ធ[25]។ ដូចលោកចៅក្រម Lavergne បានសម្រេចនៅក្នុងអង្គសវនាការ លើកទី១០៨ យ៉ាងដូច្នេះថា៖

> *ការស៊ើបអង្កេតរបស់តុលាការបានធ្វើឡើងមុនការជំនុំជម្រះនេះ គឺមានរយៈពេលរាប់ឆ្នាំមកហើយ។ហើយនៅកំឡុងពេលនៃកិច្ចស៊ើបសួរកិច្ចស៊ើបសួរត្រូវបានដាក់បញ្ចូលក្នុងសំណុំរឿងដែលក្រុមមេធាវីការពារក្តី ក៏អាចចូលមើលសំណុំរឿងនេះបានដែរហើយជនជាប់ចោទក៏អាចមើលបាន។រាល់បញ្ហាទាំងអស់ដែលចោទឡើងគឺ* [...] *ផ្អែកលើកំណត់ហេតុស្តាប់ចម្លើយសាក្សីជាលាយលក្ខអក្សរ។ព័ត៌មានទាំងអស់ដែលបានលើកឡើងគឺក្រុមរបស់លោកក៏ដូចជាក្រុមមេធាវីផ្សេងទៀតដែលតំណាងអោយជនជាប់ចោទណាម្នាក់អាចមានលទ្ធភាពមើលព័ត៌មានដែលមាននៅក្នុងកំណត់ហេតុទាំងអស់។* [...] *ក្រុម] មេធាវីការពារក្តីនិមួយៗគឺមានមេធាវីដែលជាជនជាតិខ្មែរ។ហើយមេធាវីជនជាតិខ្មែរទាំងនោះ មានលទ្ធភាពស្តាប់ និង សិទ្ធក្នុងការស្តាប់ខ្សែអាត់ស្តាប់សម្លេងទាំងនោះប្រសិនបើខ្លួនមានបំនងចង់ស្តាប់* [...] *តើមេធាវីការពារក្តីបានធ្វើ អ្វីខ្លះក្នុងកំឡុងពេលជាច្រើនឆ្នាំនៃកិច្ចស៊ើបសួររបស់តុលាការ? នេះគឺជាសំណួររបស់ខ្ញុំ។តួនាទីរបស់យើងនៅទីនេះគឺដើម្បីសិក្សា និងពិនិត្យលើបញ្ហាសំខាន់នានានៃរឿងក្តី។បញ្ហាដែលពាក់ពន្ធ័ជាមួយការស៊ើបសួររបស់តុលាការមិនត្រូវលើកយកមកពិភាក្សាគ្នាដដែលនោះទេ ព្រោះវាមិនចាំបាច់*[26] *។*

ឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធ១ នៃសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១២ រួមមានកំណត់ហេតុស្តាប់ចម្លើយសាក្សីដែលសាកសួរ ដោយស្ថាប័ន ខាងក្រៅ អ.វ.ត.ក - ជាទូទៅពុំមានផ្ទុកនូវសច្ចធារណ៍នៃភាពជឿទុកចិត្តបានទេ។ យ៉ាងណាមិញអង្គជំនុំជម្រះបាន អនុញ្ញាតឱ្យដាក់ជូន ស្របតាមវិធាន៨៧(១)[27]។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា គេមាន មូលដ្ឋានស្រប

---

[25] E96/7 *ដដែលដូចខាងលើ* ត្រង់កថាខណ្ឌទី២៦។

[26] *សេចក្តីព្រាងប្រតិចារិកចុះថ្ងៃទី០៦ ខែកញ្ញាឆ្នាំ២០១២ ទំព័រ៣៥ បន្ទាត់លេខ៣-២៥ [ប្រតិចរិកចុងក្រោយមិនទាន់អាចរកបាននៅពេលដាក់សេចក្តីសន្និដ្ឋាន]*

[27] E96/7 *ដដែលដូចខាងលើ* ត្រង់កថាខណ្ឌទី២៩។

ច្បាប់ទៅតាមទម្លាប់នៃការអនុវត្ត និងយុត្តិសាស្ត្ររបស់តុលាការ *មិនអចិន្ត្រៃយ៍ទាំងឡាយ* ដើម្បីទទួលយកកំណត់ហេតុក្នុងប្រភេទដូច្នេះ[28] ហើយអង្គជំនុំជម្រះក៏បានអនុម័តនូវអភិក្រមស្រដៀងគ្នាមួយតាមរយៈការទទួលស្គាល់[29]សញ្ញាណបង្ហាញនៃភាពអាចជឿទុកចិត្តបាន -មានដូចជា ចំណេះដឹងពីប្រភពឯកសារ ភាពស៊ីសង្វាក់គ្នា កម្រិតនៃសេចក្ដីពិស្ដារ និងកម្រិតនៃការបញ្ជាក់អះអាងទៅលើអង្គហេតុ ផ្សេងៗដែលទទួលបានពីកន្លែងផ្សេងៗ[30] - អាចជួយលើការវាយតម្លៃចំពោះតម្លៃភស្តុតាងនិងភាពទម្ងន់ និងស្របតាមលក្ខណៈវិនិច្ឆ័យសម្រាប់ការទទួលយកឯកសារដែលមានចែងក្នុងវិធាន៨៧(៣) នៃវិធានផ្ទៃក្នុង។ ជាចុងក្រោយ ពាក្យបណ្ដឹងរបស់ជនរងគ្រោះ និងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដែលនៅដាច់ៗពីគ្នាទោះបីទំនងជាផ្ដល់ "តម្លៃភស្តុតាងតិចតួច បើសិនជាមាន"[31] យ៉ាងណាក្ដីក៏អាចបញ្ជាក់លើភស្តុតាងគួរឱ្យទុកចិត្តបានផ្សេងទៀតដែរ។ ការពិចារណាត្រឹមត្រូវអំពីតម្លៃភស្តុតាងជាក់ស្ដែងលើពាក្យបណ្ដឹង និងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី គឺស្របគ្នានឹងការរកឃើញរបស់អង្គជំនុំជម្រះដែលថា កំណត់ហេតុស្ដាប់ចម្លើយជាលាយលក្ខណ៍អក្សរ "ដែលពាក់ព័ន្ធផលប៉ះពាល់នៃឧក្រិដ្ឋកម្មលើជនរងគ្រោះ" គួរតែទទួលបាន "តម្លៃភស្តុតាងខ្លះ ហើយនិងផ្ដល់នូវស្ថានទម្ងន់"[32] ព្រមទាំងស្របទៅនឹងអាណត្តិរបស់អង្គជំនុំជម្រះក្នុងការស្វែងរកការពិត។

១៤. យោងតាមមូលហេតុដែលរៀបរាប់ពីខាងលើ សហព្រះរាជអាជ្ញាសូមលើកសំណើជូនអង្គជំនុំជម្រះថា៖

(ក) ច្រានចោលសំណើសុំនេះទាំងស្រុង, ហើយនិង

(ខ) ដោយមានការអនុញ្ញាតឱ្យធ្វើកំណត់ត្រានូវការជំទាស់ទាំងឡាយតាមរបៀបណាមួយដែលអង្គជំនុំជម្រះយល់ថាសមស្រប, សូមស្នើដាក់នៅចំពោះមុខអង្គជំនុំជម្រះនូវឯកសារដែល

---

[28] សូមមើល ឧទាហរណ៍ *រដ្ឋអាជ្ញា ទល់នឹង Momčilo Perišić*, សំណុំរឿងលេខ: IT-04-81-T, សេចក្ដីសម្រេចលើញត្តិរបស់អយ្យការស្នើឱ្យទទួលយកភស្តុតាងអនុលោមតាមវិធាន៩២ស្ទួន (អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY), ចុះថ្ងៃទី២ ខែតុលា ២០០៨, ត្រង់កថាខណ្ឌ២០-៣៣។

[29] E96/7 សេចក្ដីសម្រេចលើភាពអាចទទួលយកបាន, កំណត់សម្គាល់*ខាងដើម* លេខ៥ ត្រង់កថាខណ្ឌ២៩។

[30] E158 សេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ស្របតាមវិធាន៩២ ទាក់ទិននឹងសូចនាករណ៍អំពីការជឿទុកចិត្តចំពោះឯកសារចំនួន៩៧៨ដែលពាក់ព័ន្ធនឹងសាក្សី និងអ្នកជំនាញដែលអាចកោះហៅសម្រាប់សវនាការបឋមបង្ហាញដំបូង, ចុះថ្ងៃទី២៣ ខែធ្នូ ២០១១។

[31] E96/7 សេចក្ដីសម្រេចលើភាពអាចទទួលយកបាន, កំណត់សម្គាល់*ខាងដើម* លេខ៥ ត្រង់កថាខណ្ឌ២៩។

[32] E96/7 *ដដែលដូចខាងលើ* ត្រង់កថាខណ្ឌទី២៤។

*00២/១៩-0៩-២00៧-អ.វ.ត.ក/អ.ជ.ស.ដ*

បានផ្តល់អត្ថសញ្ញាណក្នុងសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១២, ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១២ និងថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១២

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១២ | **លោកស្រី ជា លាង** សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក** Andrew CAYLEY សហព្រះរាជអាជ្ញា | | [signature] |